00641663

E24/2

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ២០១១

| ឯកសារបានទទួល |
|---|
| DOCUMENT RECEIVED/DOCUMENT REÇU |
| ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 04 / 02 / 2011 |
| ម៉ោង (Time/Heure): 9:20 |
| មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak |

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសេចក្តីកត់សម្គាល់របស់សហព្រះរាជអាជ្ញាចំពោះសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រ

---

**ដាក់ដោយ៖**

**សហមេធាវីរបស់ អៀង ធីរិទ្ធ**

លោក ផាត់ ពៅស៊ាង

កញ្ញា Diana ELLIS QC

**ផ្ញើជូន៖**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម យូ អូត្តារ៉ា

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ្រ អង្គ

Elisabeth SIMONNEAU FORT

១. នៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១១ មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ (ជនជាប់ចោទ)បានដាក់ "សំណើបន្ទាន់ស្នើសុំបន្ថែមពេលវេលា និងចំនួនទំព័រសំរាប់អញ្ញត្រកម្ម"[1] (សំណើ)។ សហព្រះរាជអាជ្ញាបានដាក់ "សេចក្តីកត់សម្គាល់របស់សហព្រះរាជអាជ្ញាចំពោះសំណើសុំរបស់មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ ស្នើសុំបន្ថែមពេលវេលា និងចំនួនទំព័រសំរាប់អញ្ញត្រកម្ម" នៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ (ចម្លើយតប)[2]។ តទៅនេះ មេធាវីការពារក្តីសូមដាក់ជូនសេចក្តីសន្និដ្ឋានតបរបស់ខ្លួនឆ្លើយតបទៅនឹងសេចក្តីកត់សម្គាល់របស់សហព្រះរាជអាជ្ញា។

២. នៅក្នុងសេចក្តីកត់សម្គាល់របស់ខ្លួន សហព្រះរាជអាជ្ញាមិនបានជំទាស់ទៅនឹងសំណើរបស់មេធាវីការពារក្តីដែលស្នើសុំបន្ថែមចំនួនទំព័រនោះទេ ក៏ប៉ុន្តែ សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងសំណើសុំឱ្យបន្ថែមពេលវេលា ដោយឱ្យហេតុផលថា:

> វិធានផ្ទៃក្នុងបានរំពឹងទុកយ៉ាងជាក់លាក់ថា ភាគីនានាអាចអាចនឹងលើកឡើងនូវអញ្ញត្រកម្មនានារួមទាំងដូចជាយុត្តាធិការនៃអង្គជំនុំជម្រះសាលាដំបូង។ [....] ការណ៍នេះមិនបង្កើតបានជា "កាលៈទេសៈពិសេស"នោះទេ។ វាគឺជាកាលៈទេសៈតាមធម្មតាមួយតែប៉ុណ្ណោះ ហើយវាត្រូវតែបានសញ្ជឹងគិតដោយអ្នកធ្វើ វិធានផ្ទៃក្នុង អវតក[3]។

៣. ទោះបីជា មេធាវីការពារក្តីនឹងត្រូវបានគេអនុញ្ញាតឱ្យបន្ថែមចំនួនទំព័រនៃអញ្ញត្រកម្មរបស់ខ្លួនពី ១៥ ទំព័រទៅ ៤៥ ទំព័រតាមការស្នើសុំ ក៏ដោយ ក៏សហព្រះរាជអាជ្ញាមិនជំទាស់ដែរ។ ចំណុចនេះបានបង្កើតឱ្យមាននូវកាលៈទេសៈពិសេសរួចទៅហើយ។ សំរាប់បញ្ហានេះវានឹងមិនអាចធ្វើបានទេ ដើម្បីដាក់ឯកសារ៤៥ទំព័រជាភាសាខ្មែរ និងភាសាអង់គ្លេសនៅក្នុងរយៈពេលពីរសប្តាហ៍នោះ។ តាមពិតទៅ ពេលវេលានេះនឹងកាន់តែតិចទៅទៀតកាលណាអង្គជំនុំជម្រះសាលាដំបូងបានសម្រេច

---

[1] សំណើបន្ទាន់របស់មេធាវីការពារក្តីស្នើសុំបន្ថែមពេលវេលា និងចំនួនទំព័រសំរាប់អញ្ញត្រកម្ម ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១១, ឯកសារលេខ: E24 ។

[2] សេចក្តីកត់សម្គាល់របស់សហព្រះរាជអាជ្ញាចំពោះសំណើសុំរបស់មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ ស្នើសុំបន្ថែមពេលវេលា និងចំនួនទំព័រសំរាប់អញ្ញត្រកម្ម" នៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១, ឯកសារលេខ: E24/1

[3] កថាខណ្ឌទី ៦ នៃសេចក្តីកត់សម្គាល់របស់ កសព ។

លើសំណើសុំបន្ទាន់នោះ។ នៅពេលថ្មីៗនេះ សហព្រះរាជអាជ្ញាខ្លួនឯងក៏បានស្នើសុំបន្ថែមពេលវេលាដោយយកសម្អាងមួយផ្នែកលើបញ្ហាបកប្រែភាសាដែរ[4] ។

៤. អង្គភាពបកប្រែភាសា(ITU)បានជូនព័ត៌មានមកឲ្យមេធាវីការពារក្តីថា: វាត្រូវការពេលវេលា១២ថ្ងៃនៃថ្ងៃធ្វើការដើម្បីបកប្រែឯកសារដែលមានចំនួន៤៥ទំព័រ គឺវាត្រូវការពេលវេលាពីរសប្តាហ៍កន្លះ[5]។

៥. សំរាប់ហេតុផលដែលបានបញ្ជាក់នៅខាងលើ មេធាវីការពារក្តីសូមស្នើអង្គជំនុំជម្រះសាលាដំបូងដើម្បីអនុញ្ញាតដូចខាងក្រោមឲ្យមេធាវីការពារក្តី:

ក. ដាក់អញ្ញត្រកម្មរបស់ខ្លួននៅក្នុងរយ:ពេលហុកសិប(៦០)ថ្ងៃបន្ទាប់ពីបានទទួលសាលដីកាសម្អាងហេតុរបស់អង្គបុរេជំនុំជម្រះ, និង

ខ. ចំនួន ៤៥ទំព័រដើម្បីតាក់តែងអញ្ញត្រកម្មរបស់ខ្លួន ។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះរបស់មេធាវី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ | ថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ២០១១ | ផាត់ ពៅស៊ាង<br>Diana ELLIS, QC | ភ្នំពេញ | AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA |

[4] សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំបន្ថែមពេលវេលាដើម្បីឆ្លើយតបទៅនឹងបណ្តឹងជំទាស់របស់ក្រុមមេធាវីការពារក្តី អៀង សារីចំពោះចៅក្រម និល ណុន ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១១, ឯកសារលេខ: E5/1 ក្នុងកថាខណ្ឌទី ៣ ។

[5] អ៊ីម៉ែលរបស់លោក អ៊ុន សុភាព ផ្ញើជូនលោក ស៊ីថា ឈិញ ហើយដែលបានបញ្ជូនបន្តមកឲ្យកញ្ញា Vera Manuello។ សូមអាននៅឯកសារភ្ជាប់ លេខ ១ ។